**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃអង្គារ ១១កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០២៣

# សេចក្តីប្រកាសព័ត៌មានរួម
# ស្តីពី
# មុខងារថ្មីរបស់ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

ក្រោយដាក់ដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដោយប្រើប្រាស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ហៅកាត់ថា CamDX កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ កន្លងទៅ, ប្រព័ន្ធនេះកំពុងពង្រីកវិសាលភាពបន្តិចម្តងៗពីត្រឹមការចុះបញ្ជីអាជីវកម្ម ឈានដល់ការផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត និងវិញ្ញាបនបត្រ លើការប្រកបអាជីវកម្មតាមវិស័យនានា។ គិតត្រឹមថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០២៣, មានក្រុមហ៊ុន/សហគ្រាសចំនួន២៥ ៦១២ ដែលបានចុះបញ្ជីអាជីវកម្មតាមរយៈប្រព័ន្ធនេះ និងមានដើមទុនវិនិយោគប្រមាណ ៧,៥៨ ប៊ីលានដុល្លារអាមេរិក។ បន្ថែមលើនេះ, ការផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត និងវិញ្ញាបនបត្រតាមវិស័យ ដែលត្រូវបានអនុម័តតាមរយៈប្រព័ន្ធនេះ មានចំនួន ៥៩៣ ដែលចេញដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងទេសចរណ៍, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, និងនិយ័តករអាជីវកម្មអចលនវត្ថុ និង បញ្ចាំ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ។

ដើម្បីបន្តផ្តល់ភាពងាយស្រួលដល់ធុរជន និងបង្កើនបទពិសោធន៍ប្រើប្រាស់កាន់តែប្រសើរជាងមុន, ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន បានបន្ថែមមុខងារចំនួន ៣ ទៀត ដែលត្រូវបានដាក់ដំណើរការចាប់ពីថ្ងៃនេះតទៅ ។ មុខងារទាំង ៣ នោះរួមមាន៖

- **មុខងារទី ១ ៖** អនុញ្ញាតឱ្យក្រុមហ៊ុន/សហគ្រាសដែលបានចុះបញ្ជីពាណិជ្ជកម្ម តែមិនទាន់ចុះបញ្ជីពន្ធដារ ឬចុះបញ្ជីពន្ធដារហើយ តែមិនទាន់ចុះបញ្ជីពាណិជ្ជកម្ម អាចបំពេញនីតិវិធីចុះបញ្ជីដែលខ្វះខាតលើប្រព័ន្ធបាន។
- **មុខងារទី ២ ៖** ការស្នើសុំផ្ទេរសិទ្ធិគ្រប់គ្រងព័ត៌មានក្រុមហ៊ុន/សហគ្រាសពីគណនី CamDigiKey មួយទៅគណនី CamDigiKey មួយទៀត។ ការស្នើសុំលើកទី ១ នឹងមិនមានការបង់កម្រៃសេវានោះទេ។ ការស្នើសុំបន្តបន្ទាប់នឹងត្រូវមានការបង់កម្រៃសេវាចំនួន ១៦០,០០០រៀល ក្នុងមួយលើកទៅកាន់ក្រសួងពាណិជ្ជកម្ម។
- **មុខងារទី ៣ ៖** ការស្នើសុំកែតម្រូវព័ត៌មានក្រុមហ៊ុន/សហគ្រាសក្រោយពេលបានដាក់ស្នើរួចរាល់ហើយ តែកំពុងស្ថិតក្នុងដំណាក់កាលបញ្ជូនត្រលប់ ដោយព័ត៌មានដែលអាចកែតម្រូវបានគឺជាព័ត៌មាន

ទាំងឡាយណាដែលក្រោយកែតម្រូវហើយមិនប៉ះពាល់ដល់ទ្រង់ទ្រាយក្រុមហ៊ុន/សហគ្រាស និងកម្រៃសេវាដែលបានទូទាត់រួចរាល់។

បន្ថែមលើមុខងារទាំង ៣ នេះ, រាល់ពាក្យស្នើសុំទាំងឡាយណាដែលទទួលបានការ "**បញ្ជូនត្រលប់**" ដើម្បីអ្នកប្រើប្រាស់អាចកែតម្រូវព័ត៌មាន ឬឯកសារ និង/ឬតម្រូវឱ្យមានការស្រាយបំភ្លឺបន្ថែមណាមួយ ប៉ុន្តែមិនបានឆ្លើយតបតាមការ "**បញ្ជូនត្រលប់**" នោះក្នុងរយៈពេល ២១ ថ្ងៃ, ពាក្យស្នើសុំនោះនឹងត្រូវធ្វើ "**មោឃភាព**"។

សម្រាប់ជំហាននៃការប្រើប្រាស់មុខងារនីមួយៗ សូមចូលទៅកាន់សៀវភៅមគ្គុទ្ទេសក៍ដែលមានលើគេហទំព័រ www.registrationservices.gov.kh ឬចូលទៅកាន់ឆាណែលយូធូប (Online Business Registration Service) ដើម្បីមើលវីដេអូណែនាំ ។ ក្នុងករណីមានសំណួរ ឬបញ្ហា សូមទាក់ទងមកកាន់ក្រុមការងារគាំទ្រតាមរយៈទូរស័ព្ទទាន់ហេតុការណ៍ 081 888 296, ទំព័រហ្វេសប៊ុក (Online Business Registration Service), អ៊ីម៉ែល (registrationservices@mef.gov.kh) និងការជជែកផ្ទាល់ (Live Chat) ដែលមានលើគេហទំព័រ www.registrationservices.gov.kh។